# ឱកាសសិក្សានៅផ្ទះ មានចែកក្រុមប៊ុគសម្រាប់ឱ្យប្រើប្រាស

ការបិទសាលារៀននៅក្នុងក្រសួងអប់រំឡុងប៊ីចនឹងបន្តរហូតដល់ថ្ងៃទី៣ខែឧសភាយ៉ាងឆាប់ ដោយសារស្ថានភាពវីរុសក្សូរ៉ូណា។ ក្រសួងអប់រំ LBUSD ចាប់ផ្តើមផ្តល់ឱកាសសិក្សានៅផ្ទះកាលពីល្ងាចម្សិលមិញ។ ឧបករណ៍ក្រុមប៊ុគបន្ថែមទៀតនឹងមានឱ្យប្រើប្រាស ចាប់ពីស្អែកទៅសម្រាប់សិស្សណាដែលត្រូវការឧបករណ៍នោះ។

ការសិក្សានៅផ្ទះនេះនឹងមិនមានផ្តល់ជាពិន្ទុទេហើយគឺសម្រាប់គាំទ្រសិស្សរហូតដល់ថ្ងៃព្រហស្បតិ៍ទី៩ខែមេសា (ថ្ងៃមុនថ្ងៃបុណ្យឈប់សម្រាកទី១០មេសានិងការឈប់សម្រាកនិទាឃរដូវសប្តាហ៍បន្ទាប់មក)។ មេរៀននិងធនធានផ្សេងៗទាំងនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការសិក្សាបន្តរបស់សិស្សនៅក្នុងកំរិតថ្នាក់និងឬកិច្ចការសិក្សារបស់សិស្ស។

នៅក្នុងរយៈពេលដែលសាលាបិទទ្វារនេះ សិស្សនិងមាតាបិតាអាចប្រើគេហទំព័រ ឱកាសសិក្សានៅផ្ទះ **Home Learning Opportunities web page** ដើម្បីស្វែងរកមើលធនធានពីសាលារៀននិងគ្រូបង្រៀននៅសាលានីមួយៗ។ គេហទំព័រនេះក៏អាចចូលទៅតាមរយៈ

- បណ្តាញបន្តភ្ជាប់ឱកាសសិក្សានៅផ្ទះនៅលើគេហទំព័រក្រសួងអប់រំនៅ **lbschools.net**.
- បណ្តាញបន្តភ្ជាប់ឱកាសសិក្សានៅផ្ទះនៅលើគេហទំព័រសាលារៀននីមួយៗ
- ដោយផ្ទាល់នៅ **lbschools.net/HLO**.

មាតាបិតា / អាណាព្យាបាលដែលនៅត្រូវការក្រុមប៊ុគសម្រាប់កូនគាត់ត្រូវតែយកអត្តសញ្ញាណប័ណ្ណដែលមានរូបរបស់គាត់ព្រម ទាំងអត្តសញ្ញាណប័ណ្ណសាលារបស់កូនគាត់ទៅសុំក្រុមប៊ុគមួយនៅសាលាណាមួយក្នុងចំណោមសាលាទាំង៥ខាងក្រោមនេះ ។ ការចែកក្រុមប៊ុគនឹងមានចែកពីម៉ោង៨ព្រឹកទៅ១១ព្រឹក ពីថ្ងៃពុធទី២៥មិនាទៅដល់ថ្ងៃសុក្រទី២៧មិនានៅតាមសាលារៀនខាងក្រោមនេះ

- វិទ្យាល័យ កាប្រ៊ីយោ Cabrillo High School, 2001 Santa Fe Ave., Long Beach
- អនុវិទ្យាល័យ ហ៊ូជ Hughes Middle School, 3846 California Ave., Long Beach
- វិទ្យាល័យ ជ័រដិន Jordan High School, 6500 Atlantic Ave., Long Beach
- វិទ្យាល័យ ឡេកវូឌ Lakewood High School, 4400 Briercrest Ave., Lakewood
- វិទ្យាល័យ ផល្លី Poly High School, 1600 Atlantic Ave., Long Beach

ដើម្បីរកមើលសាលាចែកក្រុមប៊ុគណាដែលនៅជិតផ្ទះលោកអ្នកជាងគេ សូមចូលទៅរកមើលផែនទីក្នុងគេហទំព័រ LBUSD ដោយចុចលើពាក្យ **view a map of LBUSD school locations here** ។ ការណែនាំរបៀបប្រើប្រាសក្រុមប៊ុគព្រមទាំងព័ត៌មានសម្រាប់ដាក់អ៊ិនធើនែតចុះតម្លៃនឹងមានផ្តល់ឱ្យនៅពេលទៅយកក្រុមប៊ុគ។